# ការផ្សះផ្សាជាតិ ?

ជាទម្លាប់ នៅពេលណាដែលគណបក្សកាន់អំណាច ធ្វើការគៀបសង្កត់ដោយបំពានច្បាប់, គណបក្សប្រឆាំង ឬ អ្នករងគ្រោះមិនតវ៉ាដ៏ស្វាហាប់ បែរជាសំពិន ឱ្យមានការផ្សះផ្សាជាតិទៅវិញ។ ទម្លាប់នេះ កំលាចិត្តពួកអ្នកផ្តាច់ការ ឱ្យបន្តធ្វើអំពើទុច្ចរិតគ្រប់បែបយ៉ាង ព្រោះវាគ្មានខាតអ្វីដល់ពួកគេនោះឡើយ។ ពីមួយអាណត្តិទៅមួយអាណត្តិ ពួកអ្នកផ្តាច់ការ បន្តកកេរស៊ីជាប្រព័ន្ធច្បាប់រដ្ឋ និង សិទ្ធិសេរីភាព នៃប្រជាពលរដ្ឋគ្រប់បែបយ៉ាង រហូតប្រមូលគណបក្សប្រឆាំង ឱ្យចូលមកធ្វើសហការជាមួយខ្លួន នៅក្នុងសភាជាតិ តាមករបែងចែកកៅអីកិត្តិយសមួយចំនួនតិច ដែលជារូបភាពមួយ នៃការបង្កើតគណបក្សដឹកនាំនយោបាយជាតិតែមួយ ដែលផ្ទុយពីស្មារតី នៃរដ្ឋធម្មនុញ្ញ និង គោលការណ៍ នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ ការចូលធ្វើសហការបែបនេះឯង, គណបក្សប្រឆាំងបំផ្លាញដោយខ្លួនឯង សិទ្ធអំណាចរបស់ខ្លួន ព្រោះខ្លួនចូលទៅនៅក្នុងទ្រុង នៃអំណាចផ្តាច់ការ។ ការស្វែងរក ការផ្សះផ្សាជាតិនៅក្នុងស្មារតីរៀបរាប់ខាងលើនេះ ជាអំពើប្រឆាំងនឹងរដ្ឋធម្មនុញ្ញ ព្រោះមុខការ របស់អ្នកប្រឆាំងនៅក្នុងគោលការណ៍ នៃលទ្ធិប្រជាធិបតេយ្យ គឺប្រឆាំងតាមផ្លូវច្បាប់នឹងគ្រប់អំពើណាដែលផ្ទុយពីប្រយោជន៍ជាតិ។ ដូច្នេះ បន្តមាន គំនិតរក ការផ្សះផ្សាជាតិ ជាមួយពួកជនផ្តាច់ការ នៅក្នុងបរិបទខ្មែរសព្វថ្ងៃជាគំនិតធ្ងរលុងប្រកបដោយគ្រោះថ្នាក់ជាទីបំផុត។

ឧប សៅ សន្ធា **គំនិត** ៣០ តុលា ២០១៩